# សេចក្ដីបង្រៀនជា

# គន្លឹះជំនោល

## របស់លោកដេរេក ព្រីនស៍ DEREK PRINCE

---

## ព្រះជាម្ចាស់ត្រាស់ហៅមនុស្សជាច្រើន តែព្រះអង្គជ្រើសរើសបានមនុស្សចំនួនតិចទេ

---

តើលោកអ្នកធ្លាប់ស្គាល់មនុស្សម្នាក់ដែលមានអំណោយទាន/ដុងជា"អ្នកដឹកនាំពីកំណើត" ? ឬតើលោកអ្នកស្គាល់មនុស្សដែលមានពរ ដោយគេមានសម្លេងពិរោះ ហើយលោកអ្នកហៅគេថាជាមនុស្សដែល "កើតមក" ដើម្បីច្រៀង ឬទេ? ប្រសិនបើអញ្ចឹងមែន តើលោកអ្នកធ្លាប់ធ្វើជាសាក្សី ពីមនុស្សដែលមានការឈឺចិត្តកាន់តែខ្លាំងឡើងៗ ប្រសិនបើពួកគេ មិនកំពុងធ្វើអ្វីដែលពួកគេ"កើតមក" ដើម្បីធ្វើវានោះ ឬទេ? ជាការប្រាកដណាស់ ថាវាមានភាពផ្សេងគ្នា រវាងការដែលទទួលបានការត្រាស់ហៅពីព្រះជាម្ចាស់ និងការទទួលបានការជ្រើសរើសពីព្រះជាម្ចាស់។

នៅពេលដែលព្រះគ្រីស្ទមានព្រះបន្ទូលថាៈ"ព្រះជាម្ចាស់ត្រាស់ហៅមនុស្សជាច្រើន តែព្រះអង្គជ្រើសរើសបានមនុស្សចំនួនតិចទេ" ម៉ាថាយ២២:១៤ ព្រះអង្គមិនមែនកំពុងផ្ដល់យោបល់ ឬផ្ដល់ភាពប្រហាក់ប្រហែលណាមួយទេ គឺព្រះអង្គកំពុងមានព្រះបន្ទូលពីការពិត ហើយការពិតនោះនៅតែជាសេចក្ដីពិតរហូតមកដល់សព្វថ្ងៃនេះ ដូចនៅពេលព្រះអង្គបានមានព្រះបន្ទូលពីការហ្នឹងនៅលើកដំបូងដែរ។ មានគ្រីស្ទបរិស័ទជាច្រើន បានទទួលការត្រាស់ហៅពីព្រះជាម្ចាស់ ឲ្យបម្រើក្នុងព័ន្ធកិច្ចរបស់ព្រះអង្គ ប៉ុន្តែមានគ្រីស្ទបរិស័ទចំនួនតិចទេ ដែលត្រូវបានជ្រើសរើស ហើយត្រូវបានតែងតាំងឲ្យចូលមកបម្រើក្នុងព័ន្ធកិច្ចនោះ។ គ្រីស្ទបរិស័ទខ្លះ បានទទួលការត្រាស់ហៅតាំងពីនៅវ័យកុមារម្ល៉េះ ហើយគ្រីស្ទបរិស័ទខ្លះទៀត បានទទួលការត្រាស់ហៅនៅក្នុងជីវិតពេលពួកគេមានវ័យចំណាស់ទៅហើយ។ ខ្ញុំបានរកឃើញជាញឹកញាប់ថា ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្ទបរិស័ទឲ្យបម្រើព័ន្ធកិច្ចរបស់ទ្រង់ ភាគច្រើនគឺ នៅពេលដែលពួកគេមានវ័យជំទង់ ឬក្នុងអាយុខ្ទង់២០ឆ្នាំ។ ដូច្នេះ បទគម្ពីរ ម៉ាថាយ២២:១៤ គួរតែជាចំណាប់អារម្មណ៍ជាពិសេសចំពោះអ្នកជឿដែលមានវ័យក្មេងៗ។

នៅចន្លោះពេលដែលគ្រីស្ទបរិស័ទ បានទទួលការត្រាស់ហៅពីព្រះជាម្ចាស់ឲ្យបម្រើក្នុងព័ន្ធកិច្ច និងពេលដែលពួកគេបានទទួលការតែងតាំងពីព្រះជាម្ចាស់ដោយពិតប្រាកដឲ្យចូលបម្រើក្នុងព័ន្ធ

កិច្ចនោះតែងតែមានរយៈពេលនៃការសាកល្បងមួយ ដែលជ្រៀតចូលមកយ៉ាងជិតដែរ។ជាទូទៅ ពេលគ្រីស្តបរិស័ទម្នាក់បានទទួលការត្រាស់ហៅឲ្យបម្រើក្នុងព័ន្ធកិច្ចដែលតម្រូវឲ្យមានការទទួលខុសត្រូវកាន់តែច្រើន នោះគេនឹងកាន់តែ ឆ្លងកាត់ការសាកល្បង ដែលពួកគេត្រូវតែជាប់ការសាកល្បងនោះជាមុនសិន។ មានតែអស់អ្នកណាដែលមានភាពស៊ូទ្រាំនឹងការសាកល្បងបានប៉ុណ្ណោះ ដែលទទួលបានការជ្រើសរើសឲ្យប្រតិបត្តិនូវព័ន្ធកិច្ចនោះ។ នៅក្នុងកំណ្ឌគម្ពីរចៅហ្វាយ នៅពេលលោកគេឌានផ្លុំត្រែលើកដំបូង ដើម្បីកោះហៅ ប្រជាជនអ៊ីស្រាអែល ឲ្យបម្រើព្រះជាម្ចាស់ ដើម្បីច្បាំងនឹងពួកសាសន៍ម៉ាឌាន មានបុរសចំនួន ៣២០០០នាក់ បានឆ្លើយតបតាមការកោះហៅ។ នៅពេលដែលលោកគេឌាន ដាក់ពួកអ្នកដែលដើរតាមលោកទៅក្នុងការសាកល្បង តាមបង្គាប់របស់ព្រះជាម្ចាស់ឲ្យជ្រើសរើសនោះ គឺលោកនៅសល់មនុស្សតែ៣០០នាក់ប៉ុណ្ណោះ នេះគឺមានតិចជាង១ភាគរយទេ ដែលបានទទួលការជ្រើសរើសឲ្យបម្រើព្រះជាម្ចាស់ ក្នុងចំណោមអស់អ្នកដែលបានទទួលការកោះហៅទាំងអស់។ ខ្ញុំជឿថាសព្វថ្ងៃនេះ ភាគរយក៏មិនមានអ្វីខ្ពស់ជាងពីមុនដែរ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ បានបញ្ជាក់អះអាងយ៉ាងត្រឹមត្រូវទៅតាមព្រឹត្តិការណ៍។ លោកគេឌានអាចសម្រេចការបាន ជាមួយមនុស្ស៣០០នាក់ ដែលបានទទួលការសាកល្បង និងជាមនុស្សមានវិន័យ ច្រើនជាងជាមួយមនុស្ស៣២០០០នាក់ ដែលគ្រាន់តែជាអ្នកដើរតាមលោកទៅទៀត។ គោលការណ៍ដូចគ្នានេះ ក៏ត្រូវបានអនុវត្តន៍មកទល់នឹងសព្វថ្ងៃនេះដែរ។ ម្នាក់ដែលបានទទួលការសាកល្បង បានហ្វឹកហ្វឺន ចេះដាក់វិន័យលើខ្លួនឯង ចេះបដិសេធខ្លួនឯង ជាអ្នកបម្រើរបស់ព្រះគ្រីស្ត នោះគឺមានតម្លៃស្មើនឹងគ្រីស្តបរិស័ទចំនួន១០០ នាក់ ដែលគ្រាន់តែជា"សមាជិក" នៃក្រុម ឬអង្គការ ស្ថាប័នណាមួយ។

សព្វថ្ងៃនេះមជ្ឈមណ្ឌលផ្សព្វផ្សាយដំណឹងល្អជាច្រើនរាប់តែអ្នកជឿថ្មីៗ។ ខ្ញុំជឿថាព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងការបង្កើតសិស្សច្រើនជាង។ ក្នុងអំឡុងពេលព្រះអង្គបំពេញព័ន្ធកិច្ចនៅលើផែនដីនេះ ព្រះគ្រីស្តអាចមានអ្នកប្រែចិត្តជឿថ្មីៗ ដល់ទៅរាប់ពាន់ រាប់ម៉ឺននាក់ ប៉ុន្តែនៅនាទីចុងក្រោយមុនពេលគេឆ្កាងព្រះអង្គ ព្រះអង្គនៅសល់តែសាវ័ក១១នាក់ប៉ុណ្ណោះ។ ទោះបីជាពេលដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញ និងព្រះអង្គបានបង្ហាញខ្លួនថា ទ្រង់មានព្រះជន្មរស់ ដល់មនុស្ស"ជាង៥០០នាក់"បានឃើញព្រះអង្គក្នុងពេលជាមួយគ្នាក៏ដោយ ក៏មានតែមនុស្ស១២០នាក់ប៉ុណ្ណោះដែលបានទៅបន្ទប់ជាន់ខាងលើហើយស្វែងរកឫទ្ធានុភាពពីស្ថានលើដោយព្រះអង្គ បានប្រាប់ពួកគេឲ្យរង់ចាំ ទទួលឫទ្ធានុភាពពីព្រះវិញ្ញាណបរិសុទ្ធសិន ដោយព្រមានថា បើមិនបានទទួលឫទ្ធានុភាពទេ នោះពួកគេមិនអាចធ្វើជាបន្ទាល់ពីព្រះអង្គ ដោយមានប្រសិទ្ធិភាពបានទេ។ វឌ្ឍនភាពពិតនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺតែងតែពឹងផ្អែកទៅលើគុណភាព ជាជាងលើបរិមាណ។ ថ្ងៃនេះ ដល់ពេលហើយ ដែលយើងត្រូវយកគោលការណ៍នេះ មកអនុវត្តន៍ម្តងទៀត។

# ការសាកល្បងពីរប្រភេទ

មានមធ្យោបាយធំៗពីរយ៉ាង ដែលព្រះជាម្ចាស់សាកល្បងគ្រីស្តបរិស័ទទាំងអស់ ដែលពួកគេត្រូវបានត្រាស់ហៅឲ្យមកបម្រើព្រះអង្គៈ ដោយអនុញ្ញាតឲ្យមានការលំបាក និងដោយអនុញ្ញាតឲ្យមានការងាយស្រួល។ ក្នុងប្រស្នាអំពីអ្នកព្រោះគ្រាប់ពូជ នៅក្នុងគម្ពីរម៉ាកុសជំពូក៤ ព្រះយេស៊ូបានមានព្រះបន្ទូលពីគ្រាប់ពូជ ដែលធ្លាក់លើថ្ម ហើយប្រៀបធៀបទៅនឹងគ្រីស្តបរិស័ទដែលមានភាពស៊ូទ្រាំតែមួយភ្លែត លុះដល់មានទុក្ខវេទនា ឬត្រូវគេបៀតបៀនព្រោះតែព្រះបន្ទូល គេក៏បោះបង់ចោលជំនឿភ្លាម។ ប៉ុន្តែព្រះអង្គក៏មានព្រះបន្ទូលផងដែរអំពីគ្រាប់ពូជដែលធ្លាក់លើដីមានបន្លា ដែលប្រៀបធៀបទៅនឹងគ្រីស្តបរិស័ទ ដែលមានការខ្វល់ខ្វាយអំពីជីវិតរស់នៅក្នុងលោកីយ៍ ចិត្តលោភលន់ចង់បានទ្រព្យសម្បត្តិ និងចិត្តប៉ងប្រាថ្នាផ្សេងៗ រឹបរួតព្រះបន្ទូលមិនអោយបង្កើតផលបានឡើយ។ គ្រីស្តបរិស័ទខ្លះមិនបានត្រៀមខ្លួនក្នុងការស៊ូទ្រាំនឹងការប្រឆាំង ការបៀតបៀន ការចំអកមើលងាយ ភាពឯកា ភាពក្រីក្រ ភាពបរាជ័យដែលគ្រាន់តែមើលឃើញពីសំបកខាងក្រៅព្រោះតែដំណឹងល្អ។ ចំណែកឯគ្រីស្តបរិស័ទខ្លះទៀតមិនអាចនៅតែខ្ជាប់ខ្ជួនបាននោះទេ នៅចំកណ្តាលនៃភាពស្រណុក ផាសុកភាព ភាពល្បីល្បាញ ទ្រព្យសម្បត្តិ ភាពជោគជ័យដែលលោកីយ៍ផ្តល់ឲ្យ។ អស់អ្នកណាដែលព្រះអង្គបានជ្រើសរើសទទួលឲ្យបម្រើទ្រង់នោះត្រូវតែជាមនុស្សដែលមិនពន្យាពេលដោយសារអ្វីមួយ ឬមិនជាប់ជំពាក់នឹងអ្វីផ្សេងទៀតឡើយ។

ព្រះគម្ពីរបានធ្វើការព្រមានគ្រីស្តបរិស័ថា ពួកគេត្រូវតែរំពឹងទុក ពីការទទួលការសាកល្បងជានិច្ច។ លិខិតដំបូងរបស់លោកយ៉ាកុបបានសរសេរថា "បងប្អូនអើយ ទុក្ខលំបាកគ្រប់យ៉ាងដែលបងប្អូនត្រូវឆ្លងកាត់នោះ សូមចាត់ទុកថាជាការ ដែលធ្វើអោយបងប្អូនមានអំណរដ៏បរិបូណ៌វិញ ដោយដឹងថា ការសាកល្បងមើលជំនឿរបស់បងប្អូន នឹងនាំអោយបងប្អូនចេះស៊ូទ្រាំ" (យ៉ាកុប១:២-៣)។ លោកសាវ័កពេត្រុសសរសេរថា ទុក្ខលំបាកនេះចូលមកដើម្បី "សាកល្បងជំនឿរបស់បងប្អូន ថាពិតជារឹងមាំ និងបរិសុទ្ធ។ ការសាកល្បងនេះ គឺដូចជាការប្រើភ្លើងដើម្បីបន្សុទ្ធមាសដែរ ហើយការសាកល្បងហ្នឹង នឹងធ្វើឲ្យជំនឿរបស់បងប្អូនមានតម្លៃចំពោះព្រះជាម្ចាស់ជាងមាសសុទ្ធទៅទៀត។ ដូច្នេះប្រសិនបើជំនឿរបស់បងប្អូននៅតែរឹងមាំ ដោយរងនូវការសាកល្បង យ៉ាងខ្លាំងមក នោះនៅថ្ងៃដែលព្រះយេស៊ូគ្រីស្តសំដែងខ្លួនអោយមនុស្សលោកឃើញ ជំនឿរបស់ បងប្អូននឹងទទួលការសរសើរ ទទួលសិរីរុងរឿងនិងកត្តិយសជាមិនខាន"(១ពេត្រុស១:៧)។ ការជួបប្រទះទុក្ខលំបាកយ៉ាងខ្លាំងទាំងអស់នេះវាមិនមានអ្វីចម្លែកទេសម្រាប់អ្នកដែលពិតជាគ្រីស្តបរិស័ទមែននោះ ព្រោះទុក្ខលំបាកទាំងអស់ហ្នឹង សុទ្ធតែព្រះជាម្ចាស់បានកំណត់ទុកជាមុនស្រេចហើយ។

ព្រះគម្ពីរក៏បានផ្ដល់ឲ្យយើងនូវរូបភាព ពីអ្នកបម្រើដ៏ស្មោះត្រង់របស់ព្រះជាម្ចាស់ និងការឆ្លងកាត់ការសាកល្បង ដែលពួកគេត្រូវតែជាប់។ មានឧទាហរណ៍មួយពីបុរាណនោះគឺលោក យ៉ូប។ នៅក្នុងកណ្ឌគម្ពីរយ៉ូប ២៣:១០-១២ យើងអានដឹងថាជាទីបន្ទាល់របស់លោកយ៉ូបទាក់ទងនឹងការសាកល្បងរបស់លោក: "ប៉ុន្តែ ទ្រង់ស្គាល់ផ្លូវដើររបស់ខ្ញុំ ហើយកាលណាទ្រង់បានសាកលខ្ញុំស្រេចហើយ នោះខ្ញុំនឹងចេញមកដូចជាមាស ជើងខ្ញុំបានដើរជាប់តាមជំហានទ្រង់ ខ្ញុំបានកាន់តាមផ្លូវទ្រង់ ឥតងាកបែរទៅខាងណាឡើយ ខ្ញុំមិនដែលគេចថយចេញពីបង្គាប់នៃព្រះរឹមទ្រង់ទេ ខ្ញុំបានខំប្រមូលទុកព្រះបន្ទូលនៃព្រះឱស្ឋទ្រង់ ជាជាងអាហារដែលខ្ញុំត្រូវការផង"។ នៅក្នុង ខ១២ យើងឃើញពីអាថ៌កំបាំងនៃជ័យជំនះរបស់លោក គឺទាក់ទងនឹងអាកប្បកិរិយារបស់លោកចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់។ អស់អ្នកណាដែលគោរពអោយតម្លៃចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់លើសជាងអ្វីៗផ្សេងទៀតនោះពួកគេនឹងតែងតែឆ្លងផុតពីទុក្ខលំបាកបានប្រកបដោយជោគជ័យ។ អ្នកបម្រើរបស់ព្រះជាម្ចាស់ម្នាក់ទៀត ដែលបានស៊ូទ្រាំនឹងការសាកល្បងជាច្រើននោះ គឺលោកយេរេមា។ ព្រះជាម្ចាស់បានត្រាស់ហៅលោកយេរេមា កាលពីលោកនៅក្មេងនៅឡើយ។ ការពិត ខ្លួនលោកផ្ទាល់បានគិតថា លោកនៅក្មេងពេកមិនសមនឹងធ្វើជាព្យាការីថ្លែងព្រះបន្ទូលទេ (សូមមើលយេរេមា១:៦)។ ការរងទុក្ខលំបាកចំពោះគ្រីស្តបរិស័ទវ័យក្មេង ដែលគេពិបាកស៊ូទ្រាំជាងគេបំផុតនោះ គឺភាពឯកា។ ភាពស្មោះត្រង់របស់ពួកគេចំពោះព្រះជាម្ចាស់ បានរំដោះពួកគេចេញ ពីភាពទទេឥតន័យ ភាពត្រេកត្រអាលនៃលោកីយ៍ និងសកម្មភាពដទៃទៀត ដែលពួកគេឃើញក្មេងៗអាយុស្រករវគ្នា កំពុងបណ្ដោយខ្លួនឲ្យឈ្លក់វង្វេងតាម។ ពួកគេមានអារម្មណ៍ថាខ្លួនគេឃ្លាតឆ្ងាយនៅតែឯង ត្រូវបានគេកាត់កាល់ចោលចេញ។ នៅក្នុងកណ្ឌគម្ពីរបរិទេវ៣:២៧-២៨ លោកយេរេមាបានពិពណ៌នាពីការសាកល្បងនេះថា: "ឯការដែលមនុស្សទទួលរងនឹម ក្នុងកាលដែលនៅវ័យក្មេង នោះក៏ល្អដែរ អ្នកនោះនឹងអង្គុយតែឯង ហើយនៅមាត់ស្ងៀម ពីព្រោះគឺទ្រង់ដែលដាក់នឹមលើខ្លួន"។ លោកយេរេមាបានស៊ូទ្រាំនឹងការសាកល្បងជាពិសេសនេះ ដោយខ្លួនលោកផ្ទាល់ (សូមមើលយេរេមា១៥:១៧)។ លោកយេរេមាក៏ដូចជាលោកយ៉ូបដែរ បានបញ្ចេញកម្លាំងដើម្បីស៊ូទ្រាំចេញពីអាកប្បកិរិយារបស់ខ្លួនចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នេះជាសញ្ញាសំគាល់មួយថា គាត់គឺជាអ្នកបម្រើរបស់ព្រះជាម្ចាស់ពិតប្រាកដមែន។ "ទូលបង្គំបានឃើញព្រះបន្ទូលទ្រង់ ទូលបង្គំក៏បានទទួលទានលេបចូលអស់ហើយ ព្រះបន្ទូលរបស់ទ្រង់ជាសេចក្ដីអំណរ ហើយជាទីរីករាយចិត្តដល់ទូលបង្គំ ដ្បិតឱព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារអើយទូលបង្គំបានហៅតាមព្រះនាមទ្រង់" (យេរាមា១៥:១៦)។ លោកម៉ូសេគឺជាអ្នកបម្រើរបស់ព្រះជាម្ចាស់ដ៏អស្ចារ្យម្នាក់ទៀត ដែលបានរៀនស៊ូទ្រាំក្នុងការសាកល្បងដែរ។ ការសាកល្បងលើកទីមួយរបស់លោកនោះគឺ ភាពត្រេកត្រអាល និងតំណែងខ្ពស់នៃលោកីយ៍។ លោកត្រូវបានគេនាំចូល

រស់នៅក្នុងព្រះរាជវាំងស្តេចផារ៉ោន ហើយក៏ជាអ្នកស្នងរាជ្យបន្តពីស្តេចផារ៉ោនដែរ លោកគួរតែអាចសប្បាយរីករាយជាមួយនឹងទ្រព្យសម្បត្តិ វប្បធម៌ និងប្រណិតភាពរបស់ប្រទេសអេស៊ីប។ នៅពេលលោកបដិសេធដោយមិនសុខចិត្តចាញ់សេចក្តីល្បួងនេះ គាត់ត្រូវប្រជាជនរួមជាតិរបស់គាត់បដិសេធ និងត្រូវបានព្រះចៅផារ៉ោនបៀតបៀន ហើយគាត់ត្រូវរងចាំ៤០ឆ្នាំ ដោយស៊ូទ្រាំនឹងការរត់ភៀសខ្លួន ភាពក្រីក្រ និងភាពឯកា។ តែទោះបីជាយ៉ាងណាក៏ដោយ លោកនៅតែបានយកឈ្នះលើទុក្ខលំបាកទាំងអស់នោះ ដោយសារតែលោកមិនបានអនុញ្ញាតឲ្យសិរីរុងរឿង និងទ្រព្យសម្បត្តិបណ្តោះអាសន្នទាក់ទាញ ធ្វើឲ្យលោកងងឹតមើលមិនឃើញពី សិរីរុងរឿងពិតរបស់ព្រះជាម្ចាស់ និងរង្វាន់ដ៏នៅស្ថិតស្ថេរអស់កល្បជានិច្ច ដែលព្រះជាម្ចាស់រៀបចំទុកឲ្យលោកនោះទេ។ ក្នុងគម្ពីរហេព្រើចែងថា លោកម៉ូសេបានស៊ូទ្រាំនឹងការនេះដោយសារលោក "យល់ឃើញថាលោករងការប្រមាថមើលងាយដូចព្រះគ្រីស្ត ប្រសើរជាងបានទ្រព្យសម្បត្តិនានានៅស្រុកអេស៊ីប ដ្បិតលោកជាប់ចិត្តនឹងរង្វាន់ដែលនៅខាងមុខ។ ដោយសារជំនឿ លោកបានចាកចេញពីស្រុកអេស៊ីបឥតខ្លាចស្តេចខ្ញាល់ឡើយ ដ្បិតលោកកាន់ចិត្តរឹងប៉ឹងហាក់បីដូចជាឃើញព្រះជាម្ចាស់ ដែលមនុស្សពុំអាចមើលឃើញ" (ហេព្រើ១១:២៦-២៧)។ សព្វថ្ងៃនេះមានគ្រីស្តបរិស័ទវ័យក្មេងជាច្រើនត្រូវបានកំពុងធ្វើឲ្យងងឹតចំពោះ សិរីរុងរឿងពិត និងរង្វាន់ដ៏នៅស្ថិតស្ថេរអស់កល្បជានិច្ចរបស់ព័ន្ធកិច្ចបម្រើគ្រីស្តបរិស័ទពិតប្រាកដ ដោយសំឡឹងមើលតែភាពជោគជ័យ និងផាសុកភាពនៃលោកីយ៍នេះប៉ុណ្ណោះ។

---

# ទម្ងន់នៃការត្រាស់ហៅ

---

ព្រះគម្ពីរប្រើពាក្យបី ដែលមានអំណាចទាក់ទងនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់។ ទីមួយគឺជា "ការត្រាស់ហៅដ៏ខ្ពស់" (សូមមើលភីលីព៣:១៤)។ ការត្រាស់ហៅ គឺស្ថិតពីលើកំរិតមួយដែលខុសពីចំណាប់អារម្មណ៍ទាំងឡាយ និងការទាមទារនៃជីវិត។ នៅក្នុងជីវិតរបស់គ្រីស្តបរិស័ទម្នាក់ពុំអាចមានអ្វី មានអាទិភាពខ្ពស់ជាងការត្រាស់ហៅរបស់ព្រះជាម្ចាស់នោះឡើយ មិនថាជាផ្ទះគ្រួសារ ឬចំណងនៃលោកីយ៍ "បើអ្នកណាចង់មកតាមខ្ញុំ តែមិនស្រឡាញ់ខ្ញុំខ្លាំងជាងឪពុកម្ដាយ ប្រពន្ធ កូន បងប្អូនប្រុសស្រី និងជីវិតខ្លួនទេ អ្នកនោះពុំអាចធ្វើជាសិស្សរបស់ខ្ញុំបានឡើយ" (លូកា១៤:២៦)។ ទីពីរ ការត្រាស់ហៅឲ្យបម្រើព្រះជាម្ចាស់ គឺជា"ការត្រាស់ហៅមួយដ៏វិសុទ្ធ" (សូមមើល២ធីម៉ូថេ១:៩)។ ការត្រាស់ហៅគឺជាអ្វីមួយដែលពិសិដ្ឋ និងត្រូវរក្សាការពារពីការសម្របសម្រួលទាំងឡាយ និងពីភាពសៅហ្មង ដោយមានចិត្តប្រថ្ន័ណ្ឌ។ ការត្រាស់ហៅទាមទារពេលវេលាដែលខិតខំប្រឹងប្រែងដោយការអធិស្ឋាន និងការសម្អាតខាងវិញ្ញាណដោយខ្លួនឯង។ ការសម្រេចនូវ

ការត្រាស់ហៅទាមទារ ពេលវេលារបស់យើង ការឧទ្ទិស និងការអភិវឌ្ឍគ្រប់អំណោយទាន និង ទេពកោសល្យដែលយើងមាន។ទីបី ការត្រាស់ហៅរបស់ព្រះជាម្ចាស់គឺជា "ការត្រាស់ហៅពីស្ថានសួគ៌" (សូមមើលហេប្រឺ៣:១)។ សម្លេងដែលហៅយើង ឲ្យបម្រើក្នុងព័ន្ធកិច្ចគ្រីស្តបរិស័ទនោះ ចេញមកពីស្ថានសួគ៌។ មិនថាតើ សម្លេងនោះចេញមកដូចជា "សម្លេងស្ងប់ស្ងាត់ សម្លេងតិច" ឬជា "សម្លេងនៃទឹកជាច្រើន" នោះគឺជាសម្លេងរបស់ព្រះជាម្ចាស់ដែលមានគ្រប់ព្រះចេស្តា។ សម្លេងរបស់ព្រះអង្គមានសិទ្ធិអំណាចខ្ពស់បំផុតសក្តិសមទទួលបាននូវការស្តាប់បង្គាប់ដោយឥតលក្ខខណ្ឌ។ នៅពេលដែលលោកប៉ូលបានឮការត្រាស់ហៅរបស់ព្រះជាម្ចាស់ លោកបាននិយាយថាលោក "ពុំបានទៅសួរយោបល់ពីមនុស្សណាម្នាក់ឡើយ" (កាឡាទី១:១៦)។ លោកក៏មិនបានស្វែងរកការបញ្ជាក់ ឬការអនុញ្ញាតពីមេដឹកនាំសាសនានៅប្រទេសរបស់គាត់ ឬសូម្បីតែពីអស់លោកដែលជាសាវ័ករបស់ព្រះគ្រិស្តមុនលោកដែរ។ លោកទទួលបានតែម្នាក់ឯង ជាមួយនឹងព្រះជាម្ចាស់ ដើម្បីដឹងពេញលេញពីគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់គាត់។ សព្វថ្ងៃនេះនៅពេល ដែលព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទចំពោះព័ន្ធកិច្ចជាក់លាក់ណាមួយប្រតិកម្មដំបូងរបស់ពួកគេភាគច្រើននោះ គឺស្វែងរកគំនិតរបស់អ្នកដទៃ។ តើនរណានឹងបញ្ជូនខ្ញុំ? តើនរណានឹងផ្តល់ហិរញ្ញប្បទានខ្ញុំ? ជាលទ្ធផលសម្លេងរបស់ព្រះជាម្ចាស់ត្រូវបានលិចលង់បាត់ជាឆាប់ដោយគំនិត របស់មនុស្ស។ ប៉ុន្តែចំពោះគ្រីស្តបរិស័ទដែលត្រូវបានត្រាស់ហៅ ហើយអ្នកដែលមានបំណងក្នុងការដាក់ទំនុកចិត្តទាំងអស់របស់គេលើព្រះជាម្ចាស់ នោះមានការធានាពីព្រះពរដែលចេញពីព្រះបន្ទូលផ្ទាល់របស់ព្រះអង្គថា: "ព្រះអង្គដែលបានត្រាស់ហៅបងប្អូនមក ទ្រង់មានព្រះហឫទ័យស្មោះត្រង់ ព្រះអង្គនឹងសម្រេចការនេះជាមិនខាន" (១ថែស្សាឡូនីច៥:២៤)។ ការសម្រេចនូវការត្រាស់ហៅគ្រីស្តបរិស័ទម្នាក់ គឺពឹងផ្អែកទាំងស្រុង និងអាស្រ័យលើព្រះជាម្ចាស់ផ្ទាល់តែមួយគត់។

## កុំពន្យាពេល

ចុងក្រោយការត្រាស់ហៅរបស់ព្រះជាម្ចាស់ គឺជាការបន្ទាន់។ នៅពេលដែលលោកយ៉ូស្វេបានដាក់នៅពីមុខជនជាតិអ៊ីស្រាអែល នូវការកោះហៅឲ្យបម្រើព្រះជាម្ចាស់ លោកបាននិយាយថា: "ចូរជ្រើសរើសយកព្រះណាមួយ ដែលអ្នករាល់គ្នាពេញចិត្តគោរពបំរើនៅថ្ងៃនេះទៅ" (យ៉ូស្វេ២៤:១៥)។ ទំនុកតំកើង៩៥:៧ចែងថា: "នៅថ្ងៃនេះបើឯងរាល់គ្នាឮសម្លេងទ្រង់"។ ការត្រាស់ហៅរបស់ព្រះជាម្ចាស់មិនរង់ចាំនៅលើភាពងាយស្រួលរបស់មនុស្សនោះទេ។ យើងប្រហែលជាមិនអាចពន្យាពេលការសម្រេចចិត្តរបស់យើង ដើម្បីចុះចូលនឹងទ្រង់ ដោយសារហេតុផលមួយចំនួន "រដូវ

កាលងាយស្រួល"។ អារក្សបាននិយាយថា: "នៅថ្ងៃស្អែក"ប៉ុន្តែព្រះជាម្ចាស់មានព្រះបន្ទូលថា"នៅថ្ងៃនេះ"។ នៅក្នុងគម្ពីរសុភាសិត១:២៤-៣២ មានការព្រមានប្រឆាំងនឹងការពន្យាពេល ដ៏ឧឡារិក ដើម្បីឆ្លើយតបនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់។ វាបានពិពណ៌នាអំពីមនុស្សដែល - ក្នុងភាពរុងរឿង និងភាពល្ងង់សម្រាប់ខ្លួនឯងរបស់ពួកគេ - ងាកចេញពីការត្រាស់ហៅរបស់ព្រះជាម្ចាស់។ ជាការពិតណាស់នៅពេលក្រោយ នៅពេលដែលពួកគេបានផ្លាស់ប្តូរគំនិតរបស់ខ្លួន ហើយងាកត្រឡប់ទៅស្វែងរកព្រះជាម្ចាស់វិញ នោះវាជាការយឺតពេលហើយ! ព្រះជាម្ចាស់បានដកខ្លួនចេញទៅហើយ។ សម្លេងពីមុនដែលបានត្រាស់ហៅ ឥឡូវនេះបែរជាស្ងាត់ឈឹងវិញ។ ម៉ោងនៃឱកាសបានកន្លងផុតទៅហើយ។ មិនថាតើការត្រាស់ហៅរបស់ទ្រង់ចំពោះអ្នក គឺជាការត្រាស់ហៅទូទៅ (ដូចក្នុងគម្ពីរមីកា៦:៨) ឬជាក់លាក់ (ដូចជាក្នុង១ពេត្រុស៤:១១) សូមអនុញ្ញាតអោយខ្ញុំលើកទឹកចិត្តលោកអ្នក ឱ្យយកចិត្តទុកដាក់ចំពោះការត្រាស់ហៅរបស់ទ្រង់។ ទទួលយកការត្រាស់ហៅដោយប្រាកដប្រជា។ ស៊ូទ្រាំនឹងការសាកល្បងផ្សេងៗរបស់ទ្រង់។ ថ្វាយខ្លួនរបស់អ្នក ទៅធ្វើធុរកិច្ចរបស់ស្ថានសួគ៌វិញ ដើម្បីកុំឲ្យក្លាយជាម្នាក់ទៀត ដែលមានឈ្មោះត្រូវបានបន្ថែមក្នុងពាក្យថា "ច្រើន" ដោយព្រះជាម្ចាស់បានត្រាស់ហៅ ប៉ុន្តែមិនដែលត្រូវបានជ្រើសរើសឡើយ។